ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 01 / 2016
ម៉ោង (Time/Heure): 14:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E380/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែមពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តិលើមនុស្សក្រុមគោលដៅជាក់លាក់ជនជាតិវៀតណាម ដោយសំអាងហេតុនៃសេចក្តីសម្រេចនេះនឹងត្រូវផ្តល់ជូននៅពេលក្រោយ (ឯកសារ E380, E381, E382)

1. អង្គជំនុំជម្រះទទួលបានសំណើសុំចំនួនបី ដាក់ដាច់ដោយឡែកពីគ្នាដោយមេធាវីការពារក្តី នួន ជា សហព្រះរាជអាជ្ញាទាំងពីរ និង សហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ២២ ថ្ងៃទី ២៣ និង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ ដោយសំណើទាំងនោះមួយផ្នែកស្នើសុំស្តាប់សក្ខីកម្មសាក្សីបន្ថែមអំពីអង្គហេតុនៃការប្រព្រឹត្តិលើមនុស្សក្រុមគោលដៅជាក់លាក់ជនជាតិវៀតណាម (ឯកសារ E380, E381, E382)។ អង្គជំនុំជម្រះបានស្តាប់ចម្លើយតបដោយផ្ទាល់មាត់របស់ភាគី ទៅនឹងសំណើទាំងនេះនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦។

2. មេធាវីការពារក្តី នួន ជា ស្នើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-1008, 2-TCW-823 និង 2-TCW-1009 អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដោយអះអាងថា សាក្សីទាំងនេះពាក់ព័ន្ធនឹងការប្រព្រឹត្តិមកលើជនជាតិវៀតណាមនៅសមុទ្រពីសំណាក់កងកម្លាំងយោធានៃកងពលធំលេខ ១៦៤។ សហព្រះរាជ

01187906

E380/1

អាជ្ញាទាំងពីរដាក់សំណើពីមុនរបស់ខ្លួនជាថ្មីឡើងវិញស្នើសុំស្តាប់សក្ខីកម្មសាក្សីចំនួនប្រាំនាក់ និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួនម្នាក់ (2-TCW-843, 2-TCW-957, 2-TCCP-245, 2-TCW-939, 2-TCW-849, 2-TCW-905) ពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តិលើមនុស្សក្រុមគោលដៅជាក់លាក់ ជនជាតិវៀតណាម ដោយផ្អែកលើការជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់ពួកគាត់ទៅនឹងព្រឹត្តិការណ៍នានានៅក្នុងខេត្តព្រៃវែង និង ស្វាយរៀង និង ពាក់ព័ន្ធទៅនឹងគោលនយោបាយជាតិនៃការប្រព្រឹត្តិមកលើជនជាតិវៀតណាម។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានដាក់សំណើដាច់ដោយឡែកមួយផងដែរ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-1010 និង គាំទ្រសំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-1009 ដោយបានលើកសំអាងហេតុបន្ថែមទៀត។

3. បន្ទាប់ពីបានពិចារណាលើសំណើសុំ និង ចម្លើយតបរបស់ភាគីរួចមក អង្គជំនុំជម្រះសម្រេចស្តាប់សក្ខីកម្មសាក្សី 2-TCW-1008, 2-TCW-1009 និង 2-TCW-849 និង បានស្នើសុំឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ កំណត់ពេលវេលាដែលពួកគាត់អាចចូលមកផ្តល់សក្ខីកម្មបាន។ ភាគីទាំងអស់នឹងទទួលបានការជូនដំណឹងអំពីពេលវេលាដែលត្រូវស្តាប់សក្ខីកម្មរបស់សាក្សីទាំងនេះ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន។

4. អង្គជំនុំជម្រះបដិសេធសំណើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-939, 2-TCW-905 និង 2-TCW-1010។ អង្គជំនុំជម្រះនឹងសម្រេចថាតើ ត្រូវស្តាប់ ឬមិនត្រូវស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី 2-TCW-843, 2-TCW-957 និង 2-TCCP-245 បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-844 និង 2-TCCP-869 បានផ្តល់សក្ខីកម្មរួច។ លើសពីនេះទៀត អង្គជំនុំជម្រះពន្យារការធ្វើសេចក្តីសម្រេចរបស់ខ្លួនអំពីថាតើ ត្រូវស្តាប់ ឬ មិនត្រូវស្តាប់សក្ខីកម្មសាក្សី 2-TCW-823 រហូតដល់សវនាការលើអង្គហេតុស្តីអំពីតួនាទីរបស់ជនជាប់ចោទ។

5. សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ នឹងចេញក្នុងពេលវេលាសមស្របខាងមុខ។